**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ: ៥១៤ គ.ជ.ប.ស.ស.រ**

# សេចក្តីសម្រេច
# ស្តីពី
# ការផ្តល់សុពលភាព និងដាក់ឱ្យប្រើប្រាស់បញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២៤

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៨៩ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០២៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ១៨៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់បទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

- បានឃើញសេចក្តីសម្រេចលេខ ០៥៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៤
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤

# សម្រេច

**ប្រការ១.-**

ផ្តល់សុពលភាព និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវបញ្ជីបោះឆ្នោត ឆ្នាំ២០២៤ ក្រោយពីបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៤ ដែលមានអ្នកបោះឆ្នោតសរុបចំនួន **៩,៩៩២,៤២១ នាក់** ស្មើនឹង **៨៩.០៧ ភាគរយ** ធៀបនឹងស្ថិតិប៉ាន់ស្មានប្រជាពលរដ្ឋអាយុ ១៨ ឆ្នាំឡើង ក្នុងនោះស្រីសរុបចំនួន **៥,៣០៤,៨៥៥ នាក់** និងការិយាល័យបោះឆ្នោតសរុបចំនួន **២៤,១៩០ ការិយាល័យ**។

**ប្រការ២.-**

សេចក្តីសម្រេចនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ១៥រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤
**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

ប្រាជ្ញ ចន្ទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ: គ.ជ.ប**

## តារាងលទ្ធផលផ្លូវការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៤

| ល.រ | រាជធានី ខេត្ត | ចំនួន ឃុំ សង្កាត់ | ស្ថិតិប៉ាន់ស្មាន | | ទិន្នន័យ ឆ្នាំ២០២៣ | បញ្ជីបោះឆ្នោត ឆ្នាំ២០២៤ | | | |
|---|---|---|---|---|---|---|---|---|---|
| | | | ការិ. | ១៨ឆ្នាំឡើង | | សរុបរួម | ភាគរយ | ស្ត្រី | ចំនួន ការិ. |
| 01 | បន្ទាយមានជ័យ | 67 | 1,128 | 536,061 | 441,590 | 447,973 | 83.57 | 239,308 | 1,128 |
| 02 | បាត់ដំបង | 103 | 1,709 | 836,672 | 670,663 | 677,282 | 80.95 | 356,449 | 1,709 |
| 03 | កំពង់ចាម | 109 | 1,710 | 790,052 | 663,411 | 667,650 | 84.51 | 359,562 | 1,710 |
| 04 | កំពង់ឆ្នាំង | 71 | 824 | 392,411 | 366,962 | 371,982 | 94.79 | 200,826 | 825 |
| 05 | កំពង់ស្ពឺ | 88 | 1,551 | 634,969 | 609,148 | 620,314 | 97.69 | 331,124 | 1,553 |
| 06 | កំពង់ធំ | 81 | 1,162 | 515,953 | 470,310 | 476,587 | 92.37 | 254,966 | 1,163 |
| 07 | កំពត | 93 | 1,075 | 474,260 | 430,109 | 435,026 | 91.73 | 231,973 | 1,075 |
| 08 | កណ្ដាល | 127 | 1,799 | 856,165 | 827,473 | 838,914 | 97.99 | 445,205 | 1,794 |
| 09 | កោះកុង | 29 | 197 | 95,880 | 79,818 | 80,618 | 84.08 | 40,898 | 197 |
| 10 | ក្រចេះ | 48 | 615 | 269,275 | 238,250 | 241,739 | 89.77 | 124,469 | 615 |
| 11 | មណ្ឌលគិរី | 21 | 144 | 55,083 | 52,999 | 53,850 | 97.76 | 26,729 | 144 |
| 12 | រាជធានីភ្នំពេញ | 105 | 2,247 | 1,288,488 | 962,723 | 975,382 | 75.70 | 518,681 | 2,246 |
| 13 | ព្រះវិហារ | 51 | 362 | 162,672 | 155,140 | 158,645 | 97.52 | 80,659 | 360 |
| 14 | ព្រៃវែង | 116 | 1,879 | 830,513 | 763,006 | 771,329 | 92.87 | 417,034 | 1,880 |
| 15 | ពោធិ៍សាត់ | 49 | 762 | 317,157 | 306,034 | 309,307 | 97.52 | 163,472 | 762 |
| 16 | រតនគិរី | 50 | 310 | 141,374 | 121,667 | 124,290 | 87.92 | 62,720 | 310 |
| 17 | សៀមរាប | 100 | 1,567 | 810,863 | 631,381 | 638,274 | 78.72 | 338,718 | 1,569 |
| 18 | ព្រះសីហនុ | 29 | 328 | 161,461 | 151,839 | 153,854 | 95.29 | 78,032 | 331 |
| 19 | ស្ទឹងត្រែង | 34 | 251 | 103,605 | 100,630 | 102,989 | 99.41 | 50,626 | 251 |
| 20 | ស្វាយរៀង | 80 | 1,034 | 434,424 | 422,212 | 425,020 | 97.84 | 229,090 | 1,034 |
| 21 | តាកែវ | 100 | 1,603 | 717,391 | 677,339 | 684,643 | 95.44 | 368,014 | 1,603 |
| 22 | កែប | 5 | 69 | 31,967 | 28,569 | 28,779 | 90.03 | 14,737 | 69 |
| 23 | ប៉ៃលិន | 8 | 124 | 50,878 | 46,480 | 47,126 | 92.63 | 24,059 | 124 |
| 24 | ឧត្ដរមានជ័យ | 24 | 413 | 165,197 | 155,028 | 157,163 | 95.14 | 80,248 | 413 |
| 25 | ត្បូងឃ្មុំ | 64 | 1,325 | 545,298 | 498,714 | 503,685 | 92.37 | 267,256 | 1,325 |
| **សរុប** | | **1,652** | **24,188** | **11,218,069** | **9,871,495** | **9,992,421** | **89.07** | **5,304,855** | **24,190** |

ថ្ងៃសៅរ៍ ១៥រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ប្រាជ្ញ ចន្ទ